ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
កែបថ្មីនិងឯកសារពាក់ព័ន្ធ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី
ភូមិ ៖ កែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ ៖ តែបថ្មី
ភូមិ ៖ តែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

បញ្ជីអត្ថបទ

១. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២. ផែនទីកន្លែងនេសាទសហគមន៍

៣. បញ្ជីឈ្មោះសមាជិក និងគណៈកម្មការសហគមន៍ នេសាទ និងរចនាសម្ព័ន្ធ

៤. លក្ខន្តិក:សហគមន៍នេសាទ

៥. បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៦. សេចក្តីផ្តែចការណ៍នៃការបង្កើតសហគមន៍នេសាទ

៧. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

៨. ឯកសារផ្សេងៗ

កិច្ចព្រមព្រៀង
កន្លែងនេសាទសហគមន៍

រវាង

នាយខណ្ឌរដ្ឋបាលជលផលកំពត ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាសយដ្ឋាននៅភូមិទ្វីសង្កាត់អណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ទូរស័ព្ទលេខ ០១២ ៩៣២ ៩០៩ ហៅថា " ភាគី **ក** "។

និង

ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី ជាតំណាងស្របច្បាប់ឲ្យសហគមន៍នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ទូរស័ព្ទលេខ ០១២ ១៧៣ ២២ ៧២ ហៅថា " ភាគី **ខ** "។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម ៖

ប្រការ ១.-

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃទី ខែ ឆ្នាំ ២០..... រហូតដល់ថ្ងៃទី ខែ ឆ្នាំ ២០..... ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ ។

ប្រការ ២.-

ដែននេសាទនេះមានឈ្មោះថា " កន្លែងនេសាទសហគមន៍កែបថ្មី " ដែលលាតសន្ធឹងនៅក្នុង :

- ភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ។

មាននិយាមកាដូចខាងក្រោម :

ល.រ	X	Y
១	៤០៦០២០	១១៦៧៥២៥
២	៤០៥៨២៧	១១៦៧៥១៤
៣	៤០៥៤៤០	១១៦៧៤៤២
៤	៤០៣៨៩០	១១៦៦៤៧៧
៥	៤០៥១៩៦	១១៦៣៥២៥
៦	៤០៧២២១	១១៦៣៦៩៨
៧	៤០៦៤៣២	១១៦៦១៦៥

ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

ប្រការ៣.-

ភាគី ក ត្រូវបំពេញភារកិច្ចជាអ្នកសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ។

ប្រការ៤.-

ភាគី ខ ត្រូវរៀបចំ ៖

- កន្លែងអភិរក្សព្រៃលិចទឹក ឬព្រៃកោងកាង
- កន្លែងអភិរក្សផ្កាថ្ម ឬស្មៅសមុទ្រ
- ស្រះ អាង អន្លង់ត្រីមេពូជ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក/កោងកាង
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

ប្រការ៥.-

ភាគី ខ ត្រូវរៀបចំប្រជុំពិភាក្សាអំពី ទំហំ ចំនួន ប្រវែង និងប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឲ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

ប្រការ៦.-

ភាគី ខ មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម ៖

- ការពារព្រៃលិចទឹក (ព្រៃកោងកាង) ដែលមានស្រាប់ឲ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹក សម្រាប់ដាំព្រៃលិចទឹក (កោងកាង)ឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វ ដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក (កោងកាង) ។

ប្រការ៧.-

ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឲ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម៖

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្សោតជាដើម
- លើកទំនប់ លុប ឬដឹក បឹង ព្រែក ប្រឡាយ រណ្តៅ បៀរ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ឬព្រៃកោងកាងក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធ ឬវាតដីធ្វើស្រែចំការ ស្រែអំបិល ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬដាំសាវាយ ដែលជាពូជនាំឲ្យខូចដល់បរិស្ថានធម្មជាតិ បំផ្លិចបំផ្លាញដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬផ្កាថ្ម
- ប្រមូលផល ទិញលក់ ដឹកជញ្ជូន និងធ្វើសន្និធិផ្កាថ្ម
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូសទឹកសាប
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១,៥សង្ទីម៉ែត្រ និងធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ឬទឹកប្រៃ ។

ប្រការ៨.-

ភាគី ខ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូប ឲ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

ប្រការ៩.-

ភាគី ខ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម:

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិក: បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឲ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

ប្រការ១០.-

ប្រសិនបើភាគី ខ មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឲ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ប្រការ១១.-

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្រប សហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

ប្រការ១២.-

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធ ដោយច្បាប់ចម្លងត្រូវបានប្រថាប់ត្រា ។

ថ្ងៃទី ០៩ ខែ ០៩ ឆ្នាំ ២០១៧

ភាគី ក

ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី

ហត្ថលេខា

ភាគី ខ

នាយខណ្ឌរដ្ឋបាលជលផលកំពង់

ហត្ថលេខា

សាក្សី

មេឃុំបឹងទូក

ហត្ថលេខា

ឈូច ឆៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនទីកន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី
ភូមិ ៖ កែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

ផែនដីកន្លែងទេសចរណ៍សហគមន៍កែបថ្មី

ភូមិកែបថ្មី ឃុំបឹងទូក ស្រុកគីរីឈូ ខេត្តកំពត



សញ្ញាសំគាល់

- ការប្រើប្រាស់ដីព្រៃកោង ខ្សែព្រៃស្តើង
- វាលស្មៅ
- វាលស្រែ
- ការចំការ ខ្ទមដាំក្នុងភូមិ
- ភ្នំ
- សមុទ្រ, ស្ទឹង
- ទីតាំងទេសចរណ៍សហគមន៍កែបថ្មី
- ចំហាំ ៦៨៣ ហិកតា
- ទីតាំងទេសចរណ៍នៅជាប់ព្រំ
- សាលារៀន, វត្ត
- សាលាឃុំ
- ភូមិ
- ផ្ទះ
- ផ្លូវជាតិ
- ព្រែក, អូរ
- ចំនង់, ដីឡើក
- ស្រែរំលិល
- ព្រៃកោងកាង

មាត្រដ្ឋាន ១ / ៥០០០០

COORDENATION SYSTEM

-Projection :..... UTM
-Zone :..... 48 N
-Datum :..... Indian 60
-Spheroid :..... Everest
-Unit :..... Meter

0 1 2គម

ID	X	Y
1	405681	1167459
2	405827	1167513
3	406019	1167525
4	406014	1167455
5	405672	1167411
6	405012	1166913
7	404843	1166815
8	405015	1166377
9	405488	1166123
10	406492	1166164
11	407211	1163706
12	405195	1163525
13	403893	1166776
14	404377	1166957
15	404605	1166965
16	404732	1167125
17	404648	1167386
18	405279	1167778
19	405332	1167822
20	405614	1167849
21	405469	1167585

លេខ : ០៤២/17

សូមគោរពជូន

លោកមេឃុំបឹងទូក

"ដើម្បីជូនពិនិត្យនិងសម្រេច"

កែបថ្មី ថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2017

ប្រធានគណៈកម្មការសហគមន៍ទេសចរកែបថ្មី

ស៊ុង សាវ៉ាង

លេខ : ០៤៦/17

បានឃើញនិងគោរពជូន

លោកនាយផ្នែកផ្គាយដល់ជំរើសព្រៃកន្ទោត

"ដើម្បីជូនពិនិត្យនិងសម្រេច"

បឹងទូក ថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2017

មេឃុំបឹងទូក

ហួល សុខុម

លេខ : ០៤៥/17

បានឃើញនិងគោរពជូន

លោកនាយផ្នែកផ្គាយដល់ជំរើសព្រៃកន្ទោត

"ដើម្បីជូនពិនិត្យនិងសម្រេច"

ព្រៃកន្ទោត ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៧

នាយផ្នែកផ្គាយដល់ជំរើសព្រៃកន្ទោត

ស៊ុក សំអុល

លេខ : ០៤៣/17

បានឃើញនិងគោរពជូន

លោកនាយខណ្ឌផ្គាយដល់ជំរើសកំពត

"ដើម្បីជូនពិនិត្យនិងសម្រេច"

ទឹកឈូ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៧

អភិបាលនៃគណៈអភិបាលស្រុកគីរីឈូ

ឆាត សុទណ្ឌារី

លេខ : ០៤៤/17

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត

"ដើម្បីជូនពិនិត្យនិងសម្រេច"

កំពត ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៧

នាយខណ្ឌផ្គាយដល់ជំរើសកំពត

ចាន់ រិទ្ធិ

លេខ : ០៤២/17

បានឃើញនិងគោរពជូន

លោកនាយខណ្ឌផ្គាយដល់ជំរើសកំពត

"ដើម្បីជូនពិនិត្យនិងសម្រេច"

កំពត ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៧

អភិបាលនៃគណៈអភិបាលស្រុកគីរីឈូ

ស-ស៊ុនិន

លេខ : ០៤៣/17

បានឃើញនិងគោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជូនពិនិត្យនិងសម្រេច"

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៧

ប្រធានគណៈកម្មការសហគមន៍ទេសចរកែបថ្មី

អេង ជាសាន

លេខ : ០៤៧/17

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលដែលជាប់

"ដើម្បីជូនពិនិត្យនិងសម្រេច"

កំពត ថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០១៧

អភិបាលនៃគណៈអភិបាលខេត្តកំពត

ចាន់ ចេស្តា

លេខ : ៥៤៤.....កសក

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៧

ទេព សាខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ
សហគមន៍នេសាទ និងរចនាសម្ព័ន្ធ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី

ភូមិ ៖ កែបថ្មី

ឃុំ ៖ បឹងទូក

ស្រុក ៖ ទឹកឈូ

ខេត្ត ៖ កំពត

បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ កែបថ្មី

ឃុំ បឹងឆ្នុក ស្រុកទឹកឈូ ខេត្តកំពត

ល.រ	ឈ្មោះសមាជិក	ភេទ	អាយុ	ទីលំនៅ	តួនាទី	ថ្ងៃចូលសមាជិក
១	ខៀវ សាវ៉ាង ✓	ប្រុស	៥៥	ភូមិកែបថ្មី	ប្រធានសហគមន៍	១៣/០៥/២០០៨
២	ចាន់ ជល្លា	ស្រី	៣៤	ភូមិកែបថ្មី	អនុប្រធានស/គ	១៣/០៥/២០០៨
៣	ហេង សុជា	ស្រី	៤៩	ភូមិកែបថ្មី	បេឡាស/គ	១៣/០៥/២០០៨
៤	អ៊ិន ឆុំ ✓	ប្រុស	៣៥	ភូមិកែបថ្មី	គណៈកម្មការស/គ	១៣/០៥/២០០៨
៥	ចាន់ សេង ✓	ប្រុស	២៣	ភូមិកែបថ្មី	គណៈកម្មការស/គ	១៣/០៥/២០០៨
៦	ខៀវ អ៊ុញ ✓	ប្រុស	២៤	ភូមិកែបថ្មី	គណៈកម្មការស/គ	១៣/០៥/២០០៨
៧	រត្ន មុន្នី	ប្រុស	៥៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨	ស៊ូ ហ៊ារ	ប្រុស	៤៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩	ណៃ ស៊ូន	ស្រី	៤៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០	ស៊ូ ណាង	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១១	ចាន់ ថុល	ប្រុស	២៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១២	ឆន សំបាត់	ស្រី	៦៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៣	ម៉ក់ ប៉ូ	ប្រុស	៦៧	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៤	ម៉ុក ភឿន	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៥	កយ គុណ	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៦	ជា ផៃ	ប្រុស	៣៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៧	ជា ជា	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៨	ហេង ស៊ីន	ប្រុស	៥២	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១៩	យួន ឈឿន	ប្រុស	៤១	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២០	យួន ជា	ស្រី	៣៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២១	សួស ពៅ	ប្រុស	៤៧	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២២	កែវ ថារី	ស្រី	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៣	វុង វី	ស្រី	៣៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៤	កៅ គា	ស្រី	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៥	សោ ពន	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៦	ហេង ហ៊ួន	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៧	ញ៉ែម ណុច	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៨	កៅ ជិញ	ស្រី	២៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
២៩	ខន វ៉ាត់	ប្រុស	៣៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨

៣០	ខន ថាវី	ស្រី	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣១	ជា សុភី	ស្រី	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣២	ជា ភាន់	ស្រី	២២	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៣	ម៉ែន តី	ប្រុស	៨១	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៤	ម៉ែន ភាន់	ប្រុស	៣៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៥	ម៉ែន បុត	ប្រុស	៤៧	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៦	ខៀវ ទា	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៧	ខៀន ទាន	ប្រុស	៣៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៨	គុង ស្រី	ស្រី	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៣៩	ឆនង៉ុយ	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤០	ទីន រស់	ប្រុស	៣៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤១	នួន រុន	ប្រុស	៤១	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤២	ស៊ី យាយ	ប្រុស	២៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៣	ទី ស្រី	ស្រី	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៤	ប៉ាក់ ពូន	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៥	ឈួន ប៉ាប់	ប្រុស	៣៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៦	ឈួន ប៊ិញ	ប្រុស	៤៧	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៧	ឈួន ប៊ើន	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៨	ឈួន រ័ក	ប្រុស	៣៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៤៩	បាត់ ខា	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥០	ដេញ ចក់	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥១	ដេញ រ័ចង់	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥២	ដេញ ប៉ូ	ប្រុស	៨៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៣	ចាន់ ហ៊ីវ	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៤	ចាន់ ភាស់	ប្រុស	២៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៥	កៅ ពុំ	ស្រី	៣៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៦	ខៀវ ដេត	ស្រី	៤៧	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៧	ទីន ពក	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៨	ចាន់ ជេង	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៥៩	ភាព ថាន	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦០	ខៀវ ណាំង	ស្រី	៨៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦១	ម៉ក់ ម៉ែន	ស្រី	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦២	នួន ឌិន	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៣	ពុំ កាវ	ស្រី	៣៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨

៦៤	សួស ហ័រ	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៥	ភាព ថាន	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៦	ឯម ជិន	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៧	ឯម ជូន	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៨	ចាន់ មុន	ប្រុស	២៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៦៩	កែវ ខៃ	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧០	ខៀវ ពៅ	ស្រី	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧១	កៅ កាក់	ស្រី	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧២	ហេង ទ្រី	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៣	ហេង ហៃ	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៤	ហេង ហិន	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៥	ចាន ង៉ុយ	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៦	អ៊ុក វាសនា	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៧	កែវ ដា	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៨	កែវ ទិត្យ	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៧៩	ប៉ាក ម៉ាញ	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨០	ចេក ម៉ៅ	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨១	ម៉ែង ណេង	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨២	ហេង សិន	ស្រី	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៣	តាក ណាក់	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៤	ចាន់ ប៊ិយ	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៥	ណៃ ខឿន	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៦	ណៃ ខាន	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៧	ខៀវ ទឹម	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៨	វ៉ាន់ ជា	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៨៩	ចាន់ ហិប	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩០	អ៊ុក កុ	ប្រុស	២៦	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩១	ម៉ក់ សំបាត់	ប្រុស	៤៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩២	មាស គ្រុត	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៣	មាស សុខ	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៤	ណៃ រិត	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៥	ណៃ ឃាន	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៦	អ៊ឹង ប្រុស	ប្រុស	៥៤	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៧	ទី កុង	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨

៩៨	ខេង បូរ៉ា	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
៩៩	ណៅ ខឿន	ប្រុស	២៩	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០០	ហេង ហ៊ុយ	ប្រុស	២៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០១	ទីន ពក	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០២	មេង នឿន	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០៣	ទិត្យ អិត	ប្រុស	២៣	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០៤	ទិត្យ ប៉ាប	ប្រុស	៤៥	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០៥	ណៅ កើត	ប្រុស	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
១០៦	ខៀវ ស្រីដែន	ស្រី	៥៨	ភូមិកែបថ្មី	សមាជិកស/គ	១៣/០៥/២០០៨
សរុបសមាជិកក្នុងសហគមន៍ទាំងអស់មានចំនួន: ១០៦នាក់ ស្រី ២៣នាក់						

កែបថ្មី. ថ្ងៃទី..២៥....ខែ.....១០.....ឆ្នាំ២០១២

ប្រធានគណៈកម្មការសហគមន៍នេសាទ

ខៀវ សាវ៉ាច

បានឃើញ និងឯកភាព

កែបថ្មី. ថ្ងៃទី..២៥....ខែ.....១០.....ឆ្នាំ២០១២

មេភូមិ

ឯម ថន

បានឃើញ និងឯកភាព

កែបថ្មី. ថ្ងៃទី..២៥....ខែ.....១០.....ឆ្នាំ២០១២

មេឃុំបឹងទូក

សេង ចាន់ថន

តារាងឧបសម្ព័ន្ធ

ក. បេងាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទកែបថ្មី



ខ. តួនាទី និងភារកិច្ចនិងខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

១-ប្រធានគណៈកម្មការសហគមន៍នេសាទ

- ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តន៍ការងារនៅក្នុងសហគមន៍នេសាទ
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍
- ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍នេសាទ
- សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ
- ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ
- ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍។

២- អនុប្រធានគណៈកម្មការសហគមន៍នេសាទ

- ចូលរួមអនុវត្តការងារជាមួយប្រធាន
- ជំនួសមុខឱ្យប្រធាននៅពេលអវត្តមាន
- អនុប្រធានទី ១ ទទួលបន្ទុកផ្នែកបេឡាធិការ និង អប់រំ ផ្សព្វផ្សាយ
- អនុប្រធានទី ២ ទទួលបន្ទុកផ្នែកលេខាធិការ និង ផ្នែកល្បាត។
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន។

៣- លេខាធិការ

- កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗរបស់សហគមន៍
- ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាត របស់សហគមន៍នេសាទ

- រៀបចំលិខិតអញ្ជើញ និងទីកន្លែងប្រជុំ
- ទទួលពាក្យស្នើសុំចូលជាសមាជិក និងលាលែងពីសមាជិក
- កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍នេសាទ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍
- ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ
- ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច

៤- ហេរញ្ញាធិការ

- ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល
- គ្រប់គ្រង និងចុះបញ្ជីគណនេយ្យ របស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ
- រៀបចំគំរោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ ដើម្បីគណៈកម្មការសហគមន៍ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ និងរាយការណ៍ពីស្ថានភាពចំណូល ចំណាយ ជូនគណៈកម្មការសហគន៍ជារៀងរាល់ខែ
- ស្នើសុំការឯកភាពពីសមាជិកគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកដាក់ ឯកសារឱ្យបានត្រឹមត្រូវ
- រៀបចំបែបបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក ។

៥- ផ្នែកអប់រំ ផ្សព្វផ្សាយ

- អប់រំ ផ្សព្វផ្សាយពីខ្លឹមសារលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និង សុខភាព ។ល។ ជូនដល់សមាជិកសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង
- ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំឯកសារ ផ្លាកសញ្ញា និងរូបភាពផ្សេងៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយ
- រៀបចំវគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកំពស់កំរិតយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- ធ្វើរបាយការណ៍ពីលទ្ធផលលើការងារអប់រំ និងការវាយតំលៃផែនការអនុវត្ត ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ។

៦- ផ្នែកឈ្លាត

- ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមានក្នុងដែននេសាទសហគមន៍
- ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងឈ្លាតនូវរាល់សកម្មភាពនេសាទ។ ករណីចាំបាច់ត្រូវរាយការណ៍ព័ត៌មានជូនប្រធានឱ្យបានឆាប់រហ័ស។
- សហការជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផល នៅក្នុងកន្លែងនេសាទសហគមន៍។ ក្នុង ករណីបន្ទាន់ និងចាំបាច់ ផ្នែកឈ្លាតសហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាងអាជ្ញាធរ ដែនដី ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផល ដើម្បីធ្វើការដោះស្រាយបទល្មើសទៅតាមច្បាប់

- រៀបចំផែនការល្អាត និងចាត់វិធានការការពារធនធានធម្មជាតិក្នុងកន្លែងនេសាទសហគមន៍ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព
- តាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ ដែលចូលកនេសាទក្នុងកន្លែងនេសាទសហគមន៍
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការសហគមន៍នេសាទរៀងរាល់ខែ។

ធ្វើនៅភូមិកែបថ្មី ថ្ងៃទី០៨ ខែ០៩ ឆ្នាំ ២០១១

ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី
ភូមិ ៖ កែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

១៩៦៣

លក្ខន្តិកៈសហគមន៍នេសាទ

កែបថ្មី

ឈ្មោះសហគមន៍នេសាទ: កែប ថ្មី

ភូមិ	: កែប ថ្មី
ឃុំ	: បឹង ទូក
ស្រុក	: កំពត
ខេត្ត	: កំពត

ជំពូកទី ១

គោលបំណង និងនាមករណ៍

ប្រការ ១.-

លក្ខន្តិកៈនេះមានគោលបំណង ÷

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

ប្រការ ២.-

ឈ្មោះសហគមន៍នេសាទ កែប ថ្មី ហៅកាត់ថា ស.ន.ក.ថ អាសយដ្ឋាន ភូមិ កែបថ្មី ឃុំ បឹង ទួក ស្រុក កំពត ខេត្ត កំពត។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ÷

១. ភូមិ កែប ថ្មី ឃុំ បឹង ទួក ស្រុក កំពត ខេត្ត កំពត

មានកម្មវត្ថុ: ដើម្បីរួមចំណែកគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលតំបន់ឆ្នេរឱ្យមាននិរន្តរៈភាព និងការពារព្រៃកោងកាង ស្មៅសមុទ្រ ទប់ស្កាត់បទល្មើសនេសាទ ។

ជំពូកទី ២

លក្ខខណ្ឌជាសមាជិក ភាតព្វកិច្ច និងសិទ្ធិរបស់សមាជិក

ប្រការ ៣.-

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។

ប្រការ ៤.-

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងរបៀបវារៈផ្ទៃក្នុងសហគមន៍នេសាទនេះ

- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣) នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ។

ប្រការ ៥.

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ

បង់ប្រាក់សមាជិកភាពចំនួន ៥០០ រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ ២០០៨ ២០០៨

- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ១000 រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍

ជំពូកទី ៣

លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

ប្រការ ៦.-

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

ប្រការ ៧.-

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈឹម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ។

ជំពូកទី ៤

រចនាសម្ព័ន្ធគ្រប់គ្រង និង ឯកសារផ្សេងៗ

ប្រការ ៨.-

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

ប្រការ ៩.-

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ ÷

- ការចំណាយពី ១ រៀល ដល់ ៥0000 រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ៥0001 រៀល ដល់ ៣0 0000 រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយចាប់ពី ៣0.0000 រៀលឡើងទៅត្រូវសម្រេចដោយមហាសន្និបាត ។

ប្រការ ១០.–

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ÷

- ចំណូល ចំណាយថវិកា
- សារពើភណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ប្រការ ១១.–

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានការបាយការណ៍ទូទាត់ដោយមានសក្តីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

ជំពូកទី ៥

គណៈកម្មការសហគមន៍នេសាទ

ប្រការ ១២.–

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន។

ប្រការ ១៣.–

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

ច្បាប់ ១៤.-

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

ជំពូកទី ៦

របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

ច្បាប់ ១៥.-

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាសជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

ច្បាប់ ១៦.-

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

ច្បាប់ ១៧.-

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

ជំពូកទី ៧

មហាសន្និបាតសហគមន៍នេសាទ

ប្រការ ១៨.-

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមក ហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

ប្រការ ១៩.-

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

ប្រការ ២០.-

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

ប្រការ ២១._

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

ប្រការ ២២._

មហាសន្និបាតអនុម័ត ÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

ជំពូកទី ៨

ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

ប្រការ ២៣._

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

ប្រការ ២៤.-

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងហានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

ប្រការ ២៥.-

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ។

ប្រការ ២៦.-

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម។

ជំពូកទី ៩

លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

ប្រការ ២៧.-

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភច្បាប់ធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ។

ប្រការ ២៨.-

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច។

ប្រការ ២៩.-

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់។

ប្រការ ៣០.-

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

ជំពូកទី ១០
នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ប្រការ ៣១.-

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

ជំពូកទី១១

អវសានប្បញ្ញត្តិ

ប្រការ ៣២.-

លក្ខន្តិក:សហគមន៍នសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី .....ខែ ..... ឆ្នាំ២០..... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ថ្ងៃទី ..08.. ខែ ..09.. ឆ្នាំ ២០..11.....

ប្រធានគណៈកម្មការសហគមន៍នេសាទ

ខៀវ សាវឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី

ភូមិ ៖ កែបថ្មី

ឃុំ ៖ បឹងទូក

ស្រុក ៖ ទឹកឈូ

ខេត្ត ៖ កំពត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទកែបថ្មី

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ កែបថ្មី សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

ប្រការ ១.-

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

ប្រការ ២.-

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណា ដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មក ៈសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាត តាមការសម្រេចរបស់មហាសន្និបាតប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបានគឺត្រូវអនុវត្តតាមផ្លូវច្បាប់និងបទបញ្ជាជាធរមាន។

ប្រការ ៣ .-

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការ កោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

ប្រការ ៤.-

សិទ្ធិដាក់ទណ្ឌកម្ម ៖

ក-គណៈកម្មការសហគមន៍នេសាទ

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ ដែលមានកំហុសពី ០១ (មួយ)ខែ ទៅ ០៣(បី)ខែ ក្នុង ករណីមិនរាងចាលត្រូវបណ្តេញចេញពីសមាជិកភាព
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាចញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចដើម្បីដោះស្រាយ ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងប្រកាស

គ្រង និងកិច្ចព្រមព្រៀង នៅក្នុងកន្លែងនេសាទសហគមន៍ ។

ខ-មហាសន្ធិបាត

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃ ដែលគណៈកម្មការមិនអាចដោះស្រាយបាន។

ប្រការ ៥.-

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍ នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

ក្នុងករណីសមាជិកសហគមន៍ណា ប្រើប្រាស់ឧបករណ៍ខុសច្បាប់ ត្រូវទទួលទោសចំពោះមុខច្បាប់ និងអ្នករួមផ្សំគំនិត ជាមួយជនល្មើស ត្រូវទទួលទោសលើសអ្នកប្រព្រឹត្ត ។

ប្រការ ៦.-

ក. សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទ ជាលក្ខណៈគ្រួសារ ដូចមានចែងដូចខាងក្រោម ៖

- មងត្រីក្បាក ចាប់ពី ៣,៥ សម ឡើង ប្រវែង ៥០០ម ចំនួន០៣ គ្រួសារ
- លបក្តាម ចាប់ពី ៦ សម ឡើង ចំនួន ២០០លប ៣៥ គ្រួសារ
- រនងខ្សែ រឺ លបខ្សែ ចំនួន ២០ ចំនួន ០១ គ្រួសារ
- ឈើបរុញដោយដៃ ចំនួន ០១ ចំនួន ០៧នាក់
- សំណាញ់ ០៧គ្រួសារ
- សន្ទូចបង្កៀ ០៥ គ្រួសារ
- ស្នារចាក់បង្គោ ១០ គ្រួសារ
- រាវបង្គោ ១៥ គ្រួសារ
- លូកក្តាម ០១ គ្រួសារ
- សន្ទូចរនង ចំនួន ៥០០ ផ្លែ ០៤ គ្រួសារ
- រាវក្រែង ១០ គ្រួសារ

❖ ចំពោះទំហំ ក្រឡា និងចំនួន យកតាមប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខ- ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទមួយចំនួនមានដូចខាងក្រោម ៖

- ឈិបយន្ត
- អួនអូសគូរ ឬអួនហ៊ុមរួមផ្សំភ្លើង ដែលធ្វើឱ្យត្រី ឬវារីសត្វកុំ
- មងខូវ មងកេវ
- អួនស្បៃមុងគ្របប៉ប់ប្រភេទ
- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ

- ការនេសាទដោយឧបករណ៍ឈ្នាងអូសក្រែងឈាម នៅតំបន់ឆ្នេរសមុទ្រដែលអូស ឬរុញដោយ
  កម្លាំងម៉ាស៊ីន
- ឧបករណ៍ទំនើប ឬឧបករណ៍នេសាទដែលបង្កើតថ្មី ឬរបៀបនេសាទបែបថ្មី ដែលនាំមកនូវការ
  បំផ្លាញមច្ចជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋ
  មន្ត្រីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ
- បំពុល ឬចាប់សត្វទឹកស្លាបគ្រប់ប្រភេទ
- ចាប់ ឬទិញកូនក្តាមថ្ម ក្តាមសេះ និងកូនត្រីតុក
- ហាមឃាត់ការប្រមូល ចាប់ក្តាមជ័រ ដោយការជីក គាស់ កកាយរន្ធតាមវាលភក់ ព្រៃកោងកាង
- ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ស្បៃមុងគ្រប់
  ប្រភេទ អួនអូសគូរ និងឈិបយន្តក្នុងបំណងធ្វើនេសាទ
- ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិ និងការដឹកជញ្ជូនកូនត្រី និងពងត្រី ឬពងវារីសត្វផ្សេងៗ
  ទៀត
- ការកាប់ ឆ្ការ គាស់ រាន ឈូសឆាយ និងការដុត ឬហ៊ុំព័ទ្ធកាន់កាប់ព្រៃកោងកាង
- ការគាស់កកាយយកថ្ម ដីខ្សាច់ និងរ៉ែ ដែលមាននៅក្នុងដែននេសាទ
- ការទិញ ឬការលក់សំបកពពួកខ្យង ខ្ទៅតាំងលំអរដែលជាប្រភេទកម្រ
- ការកាប់បំផ្លាញផ្តួលរំលំដើមឈើ ព្រៃកោងកាង ឬគាស់រំលើងប្រមូលគល់ឈើព្រៃកោងកាង
- ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូង ប្រភេទឈើព្រៃកោងកាងជាលក្ខណៈ
  អាជីវកម្ម ឬ ពានិជ្ជកម្ម
- ការធ្វើនេសាទ ឬការធ្វើអាជីវកម្មផ្សេងៗទៀត ដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅ
  សមុទ្រ ឬ ផ្កាថ្ម
- ការប្រមូល ការទិញ ការលក់ ការដឹកជញ្ជូន និងការធ្វើសន្និធិផ្កាថ្ម
- ការបំផ្លាញស្មៅសមុទ្រ ឬផ្កាថ្មដោយសកម្មភាពផ្សេងៗទៀត
- ការពង្រីកផ្ទៃដីស្រែ ចំការ ឬស្រែអំបិលក្នុងដែននេសាទ
- ចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយនៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ
  ឬសារធាតុពុល ឬការប្រព្រឹត្តសកម្មភាព ដែលធ្វើឱ្យពុលឬបង្កគ្រោះថ្នាក់ដល់វារីសត្ត និងវារីរុក្ខជាតិ។

ប្រការ ៧.-

សមាជិកសហគមន៍នេសាទដែល ៖

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ
  ត្រូវព្យូរ សមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយ
  មហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពី សកម្មភាពបទល្មើសជលផល
  ត្រូវព្រមាន ដោយគណៈកម្មការសហគមន៍នេសាទ

- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្កាថ្ម ឬស្មៅសមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពី ជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយ នឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់។

ប្រការ៨.-

❖ ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ហើយរស់នៅក្នុងភូមិអាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និង គោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងត្រូវបង់ភាគទានចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ក្នុងរយៈពេល ១ឆ្នាំ (មួយឆ្នាំ) បើលើសរកនេសាទរយៈពេល ពី១ឆ្នាំ (មួយឆ្នាំ) ត្រូវបង់ចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ជាថ្មីម្តងទៀត សម្រាប់ជួយទ្រទ្រង់សហគមន៍នេសាទ ផ្អែកតាមស្ថានភាពជាក់ស្តែង ដែលអនុញ្ញាតិបានដោយគណៈកម្មការសហគមន៍នេសាទ ។

❖ ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ហើយរស់នៅក្រៅភូមិអាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ។ហើយធ្វើកិច្ចសន្យា និង គោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងត្រូវបង់ភាគទានចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ក្នុងរយៈពេល ១០ថ្ងៃ (ដប់ថ្ងៃ) បើលើសរកនេសាទរយៈពេល ពី ១០ថ្ងៃ (ដប់ថ្ងៃ) ត្រូវបង់ចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ជាថ្មីម្តងទៀត សម្រាប់ជួយទ្រទ្រង់សហគមន៍នេសាទផ្អែកតាមស្ថានភាពជាក់ស្តែង ដែលអនុញ្ញាតិបានដោយគណៈកម្មការសហគមន៍នេសាទ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាម ប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ។

ប្រការ ៩.-

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី.....ខែ.....ឆ្នាំ២០.....និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅ ភ្នំប្រុស ថ្ងៃទី ០.៩ ខែ ០.៦ ឆ្នាំ ២០១១

ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី

ឈ្មោះ ស្រាង ស៊ីម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីថ្លែងការណ៍
នៃការបង្កើតសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី
ភូមិ ៖ កែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

សេចក្តីថ្លែងការណ៍

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទកែបថ្មី ដែលបានបង្កើតនៅក្នុងឆ្នាំ ២០០៧ ក្រោមការឧបត្ថម្ភបច្ចេកទេសដោយខណ្ឌរដ្ឋបាលជលផលកំពត ។

យើងខ្ញុំសូមគោរពជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ បានកើតឡើងបន្ទាប់ពីមានភាពអណាធិបតេយ្យនៃការនេសាទខុសច្បាប់ និងទំនាស់ដែននេសាទ ធ្វើឲ្យប្រជាពលរដ្ឋភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត បានឯកភាពគ្នាធ្វើសំណើសុំបង្កើតសហគមន៍នេសាទកែបថ្មីនេះឡើង និងស្របតាមគោលនយោបាយកំណែទំរង់វិស័យជលផល របស់រាជរដ្ឋាភិបាលនៅខែ តុលា ឆ្នាំ ២០០០ ។ ក្នុងគោលបំណង ការពារ គ្រប់គ្រង ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន ។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទក្នុងឆ្នាំ ២០០៧ រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា មានដាក់ស្លាកសញ្ញាផ្សព្វផ្សាយពីសារៈសំខាន់នៃធនធានជលផលដើម្បីបង្កើនការចូលរួមពីប្រជាពលរដ្ឋក្នុងការគ្រប់គ្រងធនធានជលផល ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការងារយោមល្អាតបង្ក្រាបបទល្មើស រាយការណ៍ពីសកម្មភាពផ្សេងៗទៅស្ថាប័នជំនាញ និងក្រុមប្រឹក្សាឃុំ បណ្តុះបណ្តាលការសរសេរសំណើសាមញ្ញខ្លីៗ សរសេររបាយការណ៍ និងសរសេរកំណត់ហេតុជំនាញសម្របសម្រួល រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ ផែនទីកន្លែងនេសាទសហគមន៍ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សេចក្តីថ្លែងការណ៍ និងការអភិវឌ្ឍន៍សហគមន៍នេសាទ ។ល។ ទន្ទឹមនឹងនេះ សហគមន៍នេសាទយើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារសម្រាប់បង្កើតសហគមន៍នេសាទដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ២ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមននេសាទ ដែលរួមមានបញ្ជីឈ្មោះសមាជិកសហគមន៍ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសម្រេចរបស់មហាសន្និបាត ដែលបានប្រារព្ធធ្វើនៅថ្ងៃទី ១៣ ខែ ៦ ឆ្នាំ ២០០៨ យើងខ្ញុំគណៈកម្មការតំណាងឲ្យសហគមន៍នេសាទកែបថ្មី សូមគោរពជូនលោកនាយខណ្ឌរដ្ឋបាលជលផល នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលមានភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទកែបថ្មី សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងច្បាប់លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល ។

បើសិនជាយើងខ្ញុំ បានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅភូមិកែបថ្មី ថ្ងៃទី ០៨ ខែ ០៩ ឆ្នាំ ២០១១

ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការគ្រប់គ្រងកន្លែងទេសចរណ៍សហគមន៍កែបថ្មី

រយៈពេល៣ឆ្នាំ

(២០១៧ - ២០១៩)

ភូមិ : កែបថ្មី

ឃុំ : បឹងទូក

ស្រុក : ទឹកឈូ

ខេត្ត : កំពត

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ទំព័រ

១-ស្ថានភាពទូទៅ.....១
២-អំពីប្រជាសាស្ត្រ.....១
ក- ប្រជាពលរដ្ឋ.....១
ខ-មុខរបរ.....២
៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍.....២
ក-ទីតាំង.....២
ខ-ដែននេសាទ.....២
គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.....២
ឃ-ធនធានជលផល.....៣
៤-ការធ្វើនេសាទ.....៣
ក-អ្នកនេសាទ.....៣
ខ-ឧបករណ៍នេសាទ.....៣
គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ.....៤
៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ.....៥
ក-ទស្សនៈវិស័យ.....៥
ខ-គោលបំណង.....៥
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.....៥
គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ.....៥
គ២-ផែនការកែលម្អនេសាទ.....៥
គ៣-ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស.....៦
គ៤-ផែនការគ្រប់គ្រងព្រៃកោងកាង.....៦
គ៥-ផែនការចុះឈ្មោះទប់ស្កាត់បទល្មើសនេសាទ.....៦
គ៦-ផែនការអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់សហគមន៍នេសាទ ៧
ឃ.ផែនការយុទ្ធសាស្ត្រ..... ៧
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ..... ៨
-តារាងកម្មវិធីការងារ..... ១១

ផែនការគ្រប់គ្រង
សាលាឧសាគមន៍

១- ស្ថានភាពទូទៅ

សហគមន៍នេសាទកែបថ្មី ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតលើកទី..... នៅថ្ងៃទី..... ខែ..... ឆ្នាំ២០..... និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ខែ ឆ្នាំ២០.....។

សហគមន៍នេសាទកែបថ្មី មានទីតាំងស្ថិតនៅក្នុងភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដែលមានសមាជិកសរុបចំនួន ២២៤០នាក់ ស្រីចំនួន ១១៥០នាក់ និងមានគណៈកម្មការចំនួន ៧នាក់ ស្រី ២នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុបមាន ៤៥៩គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

- ចុះល្បាតត្រួតពិនិត្យដែននេសាទសហគមន៍
- ប្រជុំពិភាក្សាកំណត់ព្រំប្រទល់ដែននេសាទសហគមន៍
- ចុះកំណត់ព្រំប្រទល់ដែននេសាទសហគមន៍
- ចូលរួមវគ្គបណ្តុះបណ្តាល
- ចូលរួមប្រជុំជាមួយភូមិ ឃុំ
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិក: បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

២- អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ២០៩១ នាក់ ប្រុស ១០០៧នាក់ ស្រី ១០៨៤នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២១នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២០នាក់ ស្រី ០៥នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៨នាក់ ស្រី ១២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទចំនួន ១២នាក់ ស្រី ០៤នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ៩០% ។ ក្រៅពីនេះមានអ្នកកាន់សាសនាកាតូលិកប្រមាណ ១០%
- មិនចេះអក្សរមានចំនួន ៣៥នាក់ ស្រី ១៥នាក់
- កំរិតថ្នាក់បឋមសិក្សាចំនួន ១០០នាក់ ស្រី ៦០នាក់
- កំរិតអនុវិទ្យាល័យចំនួន ៦០នាក់ ស្រី ៣៥នាក់
- កំរិតថ្នាក់វិទ្យាល័យចំនួន ១៥នាក់ ស្រី ០៨នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

-ធ្វើស្រែចំនួន	៣០គ្រួសារ ទំហំ ៥៤ហិកតា
-ធ្វើនេសាទចំនួន	៥៦គ្រួសារ
-ធ្វើស្រែ និងនេសាទចំនួន	៣២០គ្រួសារ ទំហំដី ១២១ហិកតា
-ធ្វើចំការចំនួន	៣០គ្រួសារ ទំហំដី ៣០ហិកតា
-ចិញ្ចឹមសត្វចំនួន	៣២០គ្រួសារ
-លក់ដូរចំនួន	៧០គ្រួសារ
-ជាងផ្ទះចំនួន	១០គ្រួសារ
-កែច្នៃផលនេសាទ	០៨គ្រួសារ
-កម្មករចល័ត	១៥០គ្រួសារ។

៣- អន្លង់នេសាទសហគមន៍ និងធនធានដែលមាននៅក្នុងអន្លង់នេសាទសហគមន៍

ក. ទីតាំង

អន្លង់នេសាទសហគមន៍កែបថ្មីមានទំហំ ៦៨៣ហិកតា ដែលនិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។ មានព្រំប្រទល់៖

- ខាងកើតជាប់នឹងសហគមន៍នេសាទទទឹងថ្ងៃ
- ខាងលិចទល់នឹងកំពតផត
- ខាងជើងទល់នឹងក្រុមហ៊ុនកែវជា
- ខាងត្បូងជាប់នឹងខោសទឹកថ្លា

ខ. ដែនដនេសាទ

អន្លង់នេសាទសហគមន៍កែបថ្មី មានព្រែកចំនួន ៣ ។

- ព្រែកក្បៀ	បណ្តោយ ៥០០ម៉ែត្រ	ទទឹង ១០ម៉ែត្រ	នេសាទពេញ ១ឆ្នាំ
- ព្រែកតាឈឹម	បណ្តោយ ៥០០ម៉ែត្រ	ទទឹង ២០ម៉ែត្រ	នេសាទពេញ ១ឆ្នាំ
- ព្រែកតាដោក	បណ្តោយ ៥០០ម៉ែត្រ	ទទឹង ០៨ម៉ែត្រ	នេសាទពេញ ១ឆ្នាំ

- ព្រៃកោងកាងទំហំ ៣ហិកតា។

គ. តំបន់ដែលមានលទ្ធភាពបង្កើតអន្លង់អភិរក្ស

- ខោសកណ្តាលមានទំហំ ២០ហិកតា អភិរក្សជីវចម្រុះ។

- ប្រភេទត្រី:

ត្រីស ត្រីក្បាលកាហែង ត្រីក្ពុកស ត្រីកន្តាំង ត្រីក្ពុកស ត្រីកាបេ ត្រីចាប ត្រីអណ្ដែ ត្រីកិ ត្រីឌីឈាវ ត្រីកាវ៉ាវ ត្រីចង្កោមបី ត្រីក្តចិន ត្រីប្រម៉ា ត្រីកាម៉ុង ស្លឹកឬស្សី ត្រីកន្ទុយរឹង ត្រីផ្ទោង ត្រីទឹកកែ ត្រីផ្ទក់សមុទ្រ ត្រីអណ្តែងប៉ុយ ត្រីអណ្តែងកាវាំង បបែល ត្រីត្រសក់ ត្រីអាំងកឺយ ត្រីដូរអង្ករ ត្រីកាំគួច ត្រីសំបោហៀរ កាពត, ត្រីគីង្គក់ .....។ល។

- ប្រភេទវារីសត្ត:

ក្តាមសាច់ បង្គា ក្តាមថ្ម ក្តាមសេះ ក្តាមផ្ទរលាន់ ក្តាមជីរ មឹក ក្រែងឈាម ងាវ ងាវភក់ ងាវស បង្កង បង្កងប៉ាក អណ្តើក កន្ទាយ បល្ល័ងកាស អន្ទង់ ផ្សោតប៉ាវ៉ា ល្មិច ពស់ទឹក ....។ល។

- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ:

ព្រៃកោងកាង ក្រញឹមស ស្មៅសមុទ្រ ផ្តាថ្ម សារាយ ស្មៅត្រយ៉ុង ស្លែ ប្រង់ អម្ពា តាប៊ុន ចាក ត្រចៀកក្រាញ់ ស្មាច ខ្ជុយ .....។ល។

៤- ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍ចំនួន ១២០នាក់ ស្រី ១០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៥០នាក់ ស្រី ១០នាក់
- អ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ១០០នាក់ ស្រី ០៥នាក់

ខ. ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

ប្រភេទឧបករណ៍	ឯកតា	ចំនួនគ្រួសារ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ..... ខែណា?)
ឈឹបរុញដៃ	គ្រឿង	១៥	បណ្តោយ៧ម៉ែត្រ ទទឹង៥ម៉ែត្រ	ពេញ១ឆ្នាំ
សន្ទូចរនង	ខ្សែ	៣	៩០០ផ្លែ	រដូវប្រាំង
រនងខ្សង	ខ្សង	១០	ចំនួន ២០០ខ្សង	រដូវប្រាំង
លបក្តាម	លប	៣០	ក្រឡាចាប់ពី ៤សង់ទីម៉ែត្រ ចំនួន ២០០លប	ពេញ១ឆ្នាំ
មងត្រី	ម៉ែត្រ	៤	ក្រឡាចាប់ពី ៣,៥សង់ទីម៉ែត្រ ប្រវែង ៥០០ម៉ែត្រ	ពេញ១ឆ្នាំ
ស្នរចាក់បង្គា	គ្រឿង	១០	ចំនួន ១គ្រឿង	ពេញ១ឆ្នាំ
រាវបង្គា	នាក់	១៥		ពេញ១ឆ្នាំ

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីន	៤០	១តោន-១,៥តោន	៥-១៥
ទូកចែវ	ត្មាន		

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

ប្រភេទឧបករណ៍	ឯកតា	ចំនួនគ្រួសារ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ..... ខែណា?)
ឈឺបរុញដៃ	គ្រឿង	៥	បណ្តោយ៧ម៉ែត្រ ទទឹង៥ម៉ែត្រ	ពេញ១ឆ្នាំ
សន្ទូចរនង	ខ្សែ	២	៩០០ផ្លែ	រដូវប្រាំង
រនងខ្សែ	ខ្សែ	៣	១៥០០ខ្សែ	រដូវប្រាំង
លបក្តាម	ចំនួន	១៥	៣0000	ពេញ១ឆ្នាំ
មងត្រី	ម៉ែត្រ	២	៦00	ពេញ១ឆ្នាំ

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីន	១0	១តោន-១,៥តោន	៥-១៥
ទូកចែវ	គ្មាន		

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមកពីក្រៅសហគមន៍នេសាទ

ប្រភេទឧបករណ៍	ឯកតា	ចំនួនគ្រួសារ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍
មងខូយ	ម៉ែត្រ	៣	១៥00ម៉ែត្រ	ពេញ១ឆ្នាំ
លបក្តាម	ចំនួន	២0	៤0000លប	ពេញ១ឆ្នាំ
មងត្រី	ម៉ែត្រ	៣	៩00ម៉ែត្រ	ពេញ១ឆ្នាំ
ទូកអូស	ទូក	២៥	ប្រវែង ២0 ទៅ ៣0ម៉ែត្រ	

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកម៉ាស៊ីនលើ	១២	១តោន-១,៥តោន	៦-១៥
ទូកម៉ាស៊ីនបាត	៣	២តោន-៣តោន	១៥-២២

គ. ការប៉ាន់ប្រមាណផលនេសាទចាប់ប្រចាំឆ្នាំ

ប្រភេទផលនេសាទ	បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម)		
	រដូវប្រាំង	រដូវវស្សា	សរុបប្រចាំឆ្នាំ
ត្រី	៥0	១៥0	២00
ក្តាមសេះ	៣៥0	២៥0	៦00
បង្គា	៥0	៧0	១២0
សរុប	៤៥0	៤៧0	៩២0

៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ

សហគមន៍នេសាទកែបថ្មី មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីឡូតិ៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាពនិងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែនេងសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

ឈ្មោះ/ទីតាំងកន្លែងនេសាទ	ពេលវេលាធ្វើនេសាទ	ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ		
		ប្រភេទ	ទំហំ/ប្រវែង	ចំនួន
-ក្រឡុកយ៉ាង -កោះក្តាន់ -មុខកោះខ្នុះ -មុខក្តាត -មុខគីឡូ១២	ពេញ១ឆ្នាំ	មងត្រីក្បាក	ចាប់ពីក្រឡា ៣សង់ទីម៉ែត្រ ប្រវែង ៥០០ម៉ែត្រ	៥០០ម៉ែត្រ
		មងក្តាម	ក្រឡាពី៤សង់ទីម៉ែត្រ ចំនួន ២០០លប	២០០លប
		រនងខ្យ/លបខ្យង	ចំនួន ២០០ខ្យង	២០០ខ្យង
		ឈើបរុញដៃ	ចំនួន ១គ្រឿង	០១គ្រឿង
		សន្ទូចរនង	ចំនួន ៥០០ផ្លែ	៥០០ផ្លែ
		ស្នរចាក់បង្គា	ចំនួន ០១គ្រឿង	០១គ្រឿង
		រាវបង្គា		
		លូកក្តាម		

គ២- ផែនការលម្អដែននេសាទ

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមានក្នុងតារាងខាងក្រោម៖

ឈ្មោះដែននេសាទ	ទំហំ	ទំហំដែលត្រូវកែលម្អ	សកម្មភាព	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ព្រៃកតាឈឹម	១០០០០ម៉ែត្រ	១០០០០	ស្តារព្រៃក	ខែមករា	ខែមិថុនា
តាមបណ្តោយឆ្នេរ	៣០មX៥០០០ម	៣០មX៥០០០ម	ដាំកូនកោងកាង		

គ៣- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ឈ្មោះផែននេសាទ	ទំហំ	ប្រភេទនៃការអភិរក្ស	សកម្មភាព	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ខោសកណ្តាល	២០ហិកតា	ជីវចម្រុះ	-ផ្សព្វផ្សាយ -បោះបង្គោល -ស្លាកសញ្ញា -យាមល្បាត	០១ ខែមករា ឆ្នាំ២០១៧	៣១ ខែធ្នូ ឆ្នាំ២០១៩

គ៤- ផែនការគ្រប់គ្រងកោងកាង

ឈ្មោះផែននេសាទ	ទំហំ	ប្រភេទកូនឈើដែលត្រូវការពារ	សកម្មភាព	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ព្រៃលិចទឹក	០៣ហិកតា	កោងកាង	-ផ្សព្វផ្សាយ -បោះបង្គោល -ស្លាកសញ្ញា -យាមល្បាត	០១ ខែមករា ឆ្នាំ២០១៧	៣១ ខែធ្នូ ឆ្នាំ២០១៩

គ៥- ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

សកម្មភាព	គោលបំណង	លទ្ធផលរំពឹងទុក
ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍នេសាទ	ដើម្បីឱ្យអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធមានការចូលរួមសហការ និងជួយជម្រុញការអនុវត្តឱ្យបានសមស្របតាមផែនការគ្រោងទុករបស់សហគមន៍នេសាទ	អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធមានការគាំទ្រ និងចូលរួមរាល់សកម្មភាពដែលបានអនុវត្តរបស់សហគមន៍នេសាទមានភាពទទួលខុសត្រូវស្របទៅតាមគោលការណ៍ណែនាំច្បាប់
ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋនិងសមាជិក សហគមន៍នេសាទ	សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋយល់ដឹងអំពីវិស័យជលផល និងបរិស្ថាន ហើយចូលរួមទប់ស្កាត់បទល្មើសនេសាទដើម្បីថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព	សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុង និងក្រៅចូលរួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធ៌ម និងការបំផ្លាញធនធានធម្មជាតិត្រូវបានថយចុះ
ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទរៀបចំផែនការប្រចាំខែ	ដើម្បីឆ្លុះបញ្ចាំងនិងកំណត់ផែនការដែលបានអនុវត្ត ពង្រឹងសមត្ថភាពលើ	គណៈកម្មការសហគមន៍ បានទទួលនូវបទពិសោធន៍និងចំណេះ

នឹងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋនិងសមាជិក សហគមន៍នេសាទ	និងបរិស្ថាន ហើយរួមទប់ស្កាត់បទល្មើសនេសាទដើម្បីថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព	រួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធ៌មនិងការបំផ្លាញធនធានធម្មជាតិត្រូវបានថយចុះ
ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទរៀបចំផែនការប្រចាំខែ និងត្រីមាស	ដើម្បីឆ្លុះបញ្ចាំងនិងកំណត់ផែនការដែលបានអនុវត្ត ពង្រឹងសមត្ថភាពលើការអនុវត្ត និងរៀបចំផែនការបន្តសំដៅទៅលើការអនុវត្តឱ្យទទួលបានជោគជ័យ	គណៈកម្មការសហគមន៍ បានទទួលនូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើការដោះស្រាយ និងមានការកែលម្អកាន់តែប្រសើរឡើង
សហការជាមួយស្ថាប័ន្ធជំនាញ សមត្ថកិច្ច និងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស	ដើម្បីបង្កើនកិច្ចសហការរវាងសហគមន៍និងអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការចុះបង្ក្រាបបទល្មើសនេសាទ	ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ និងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍នេសាទកែបថ្មី

គ៦- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

ប្រភេទប្រាក់ចំណូល	សកម្មភាព	ថ្ងៃខែឆ្នាំចាប់ផ្តើម	ថ្ងៃខែឆ្នាំបញ្ចប់	ចំណូលសរុប	ផ្សេងៗ
ភាគទានពីសមាជិកសហគមន៍នេសាទ	-ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី -ដើរប្រមូលភាគទានតាមផ្ទះសមាជិក	ខែ០៣ ឆ្នាំ២០១៧	ខែ០៣ ឆ្នាំ២០១៩	៣៣៦០០០	
ភាគទានប្រចាំឆ្នាំ	-ផ្សព្វផ្សាយជូនដំណឹងមុខរយៈពេល១៥ថ្ងៃ -ដើរប្រមូលភាគទានតាមផ្ទះសមាជិក	ពាក់កណ្តាលខែ១១ ឆ្នាំ២០១៧	ពាក់កណ្តាលខែ១១ ឆ្នាំ២០១៩	៦៧២០០០	
សរុប				១០០៨០០០	

ឃ- យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន: សមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស

ព្រៃលិចទឹក ដីសួនអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកា ទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

តារាងសង្ខេបផែនការគ្រប់គ្រងតំបន់ទេសចរណ៍សហគមន៍តែមថ្មី
រយៈពេល៣ឆ្នាំ (២០១៧ ដល់ ២០១៩)

ប្រភេទផែនការ	សកម្មភាព	លទ្ធផលរំពឹងទុក	ការប៉ាន់ស្មានចំណាយ(រៀល)	ប្រភពចំណូល	ពេលចាប់ផ្តើម	ពេលបញ្ចប់	ផ្សេងៗ
១.ការប្រើប្រាស់ឧបករណ៍នេសាទ	ប្រជុំផ្សព្វផ្សាយអំពីផែនការការប្រើប្រាស់ឧបករណ៍នេសាទ	-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តផែនការប្រើប្រាស់ឧបករណ៍នេសាទ -ផលត្រីក្នុងសហគមន៍នេសាទមានការកើនឡើង -ប្រជាពលរដ្ឋអាចនេសាទបានពេញ១ឆ្នាំ	៣00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ		១៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ចែកផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទតាមផ្ទះ		១៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ		២៨0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
២.ការកែលម្អដែននេសាទ	ដាំកូនកោងកាង	សំបូរព្រៃកោងកាងផលនេសាទក្នុងសហគមន៍មានការកើនឡើង	១៥00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ស្តារព្រៃក	ធ្វើឱ្យព្រៃកមានជម្រៅជ្រៅធនធានជលផលមានការកើនឡើង	១២ 000 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ	សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅចូលរួមថែរក្សា និងការពារធនធានធម្មជាតិ	១៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ចុះកំណត់ព្រំប្រទល់កន្លែង	តំបន់អភិរក្សមានព្រំប្រទល់	១២ 000000		២០១៧	២០១៩	

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងទេសាចរសហគមន៍កែបថ្មី
រយៈពេល៣ឆ្នាំ (២០១៧ ដល់ ២០១៩)

ប្រភេទផែនការ	សកម្មភាព	លទ្ធផលរំពឹងទុក	ការប៉ាន់ស្មានចំណាយ(រៀល)	ប្រភពចំណូល	ពេលចាប់ផ្តើម	ពេលបញ្ចប់	ផ្សេងៗ
១.ការប្រើប្រាស់ឧបករណ៍នេសាទ	ប្រជុំផ្សព្វផ្សាយអំពីផែនការការប្រើប្រាស់ឧបករណ៍នេសាទ	-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តផែនការប្រើប្រាស់ឧបករណ៍នេសាទ -ជលត្រីក្នុងសហគមន៍នេសាទមានការកើនឡើង -ប្រជាពលរដ្ឋអាចនេសាទបានពេញ១ឆ្នាំ	៣00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ		១៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ចែកផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទតាមផ្ទះ		៧៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ		២៤0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
២.ការកែលម្អដែននេសាទ	ដាំកូនកោងកាង	សំបូរព្រៃកោងកាងជលនេសាទក្នុងសហគមន៍មានការកើនឡើង	១៥00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ស្តារព្រៃក	ធ្វើឱ្យព្រៃកមានជម្រៅជ្រៅធនធានជលផលមានការកើនឡើង	១២ 000 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ	សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅចូលរួមថែរក្សា និងការពារធនធានធម្មជាតិ	១៥0 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	ចុះកំណត់ព្រំប្រទល់កន្លែង	តំបន់អភិរក្សមានព្រំប្រទល់	១២ 000000		២០១៧	២០១៩	

៣.ផែនការកំណត់និង ការរៀបចំកន្លែងអភិរក្ស	អភិរក្ស	ច្បាស់លាស់					
	ធ្វើស្លាកសញ្ញាហាមឃាត់ ចំនួន ០២ផ្ទាំង	សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងនិងក្រៅ ចូលរួមថែរក្សា និងការពារ ធនធានធម្មជាតិ	៣ ៨០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
	ល្បាតជាប្រចាំនៅកន្លែងអភិរក្ស	សមាជិកក្រុមល្បាត ចូលរួម ល្បាតតមផែនការ ៣ដង/ខែ	៦០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
៤.ការគ្រប់គ្រង ព្រៃកោងកាង	ប្រជុំរៀបចំផែនការឬក្រប់គ្រង ព្រៃកោងកាង	-ធនធានជលផលនឹងកើនឡើង -ព្រៃកោងកាងមាននិរន្តរភាព	៣០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
	ផ្សព្វផ្សាយផែនការប្រើប្រាស់ ព្រៃកោងកាង		១៥០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
	ប្រមូលគ្រាប់កោងកាង		២៤០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
	បណ្តុះកូនកោងកាង ដាំ និងថែ រក្សា ការពារ និងកាប់រំលោះ		៣០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
	ទំនាក់ទំនងជាមួយស្ថាប័នលើ ការគ្រប់គ្រងសហគមន៍នេសាទ	អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធ មានការគាំទ្រ និងចូលរួម រាល់សកម្មភាពផ្សេងៗ	៦០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	
៥.ការចុះល្បាតទប់ស្កាត់ បទល្មើសនេសាទ	ផ្សព្វផ្សាយពីច្បាប់ជលផល និងបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធដល់ប្រជាពលរដ្ឋ	សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងនិងក្រៅ ចូលរួមថែរក្សា និងការពារ ធនធានធម្មជាតិ និងការ បំផ្លិចផ្លាញធនធានធម្មជាតិ	១៥០០ ០០០	រដ្ឋបាលជលផល	២០១៧	២០១៩	

		ត្រូវបានថយចុះ					
	ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទ រៀបចំផែនការប្រចាំខែ និងត្រីមាស	គណៈកម្មការសហគមន៍នេសាទទទួលបានបទពិសោធន៍និងចំណេះដឹងថ្មីៗលើការដោះស្រាយបញ្ហានិងមានការកែលម្អកាន់តែប្រសើរ	៣00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
	សហការជាមួយស្ថាប័នជំនាញសមត្ថកិច្ចនិងសហគមន៍ជិតខាងក្នុងការបង្ក្រាបបទល្មើសនេសាទ ៣ដង/ខែ	ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយនិងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍	៦00 000	រដ្ឋបាលជលផល	២០១៧	២០១៩	
៦.ផែនការថវិការសម្រាប់ទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ	ភាគទានពីសមាជិកសហគមន៍	-ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី ៣០នាក់/ឆ្នាំ -ដើរប្រមូលភាគទានតាមផ្ទះ:	៤៥000	សហគមន៍	២០១៧	២០១៩	
	ភាគទានប្រចាំឆ្នាំ	សមាជិកសហគមន៍នេសាទនឹងចូលរួមបង់ភាគទានរៀងរាល់ឆ្នាំ	៤២៦000	សហគមន៍	២០១៧	២០១៩	
សរុប			**៣៧៩01000**				

តារាងកម្មវិធីការងារ

សកម្មភាព	ពេលវេលា																																			
	២០១៧												២០១៨												២០១៩											
	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២
១- ការប្រើប្រាស់ឧបករណ៍នេសាទ																																				
ប្រជុំផ្សព្វផ្សាយអំពីដែនការប្រើប្រាស់ឧបករណ៍នេសាទ																																				
បិទផ្សាយដែនការប្រើប្រាស់ឧបករណ៍នេសាទ																																				
ចែកផ្សាយឯកសារដែនការប្រើប្រាស់ឧបករណ៍នេសាទតាមផ្ទះ																																				
ផ្សាយតាមមេក្រូនូវដែនការប្រើប្រាស់ឧបករណ៍នេសាទ																																				
២-កែលម្អដែននេសាទ																																				
ដាំកូនកោងកាង																																				
ស្ពារព្រែក																																				
ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ																																				
៣.ដែនការកំណត់និងរៀបចំកន្លែងអភិរក្ស																																				
ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ																																				
ចុះកំណត់ព្រំប្រទល់កន្លែងអភិរក្ស																																				
ធ្វើស្លាកសញ្ញាហាមឃាត់ ចំនួន ០២ផ្ទាំង																																				
ល្បាតជាប្រចាំនៅកន្លែងអភិរក្ស																																				


៤.ផែនការគ្រប់គ្រងព្រៃកោងកាង
ប្រជុំរៀបចំផែនការឬគ្រប់គ្រងព្រៃកោងកាង
ផ្សព្វផ្សាយផែនការប្រើប្រាស់ព្រៃកោងកាង
ប្រមូលគ្រាប់កោងកាង
បណ្តុះកូនកោងកាង ដាំ និងថែរក្សាការពារ និងកាប់រំលោះ
ទំនាក់ទំនងជាមួយស្ថាប័នលើការគ្រប់គ្រងសហគមន៍នេសាទ
៥.ការចុះឈ្មោះទប់ស្កាត់បទល្មើសនេសាទ
ផ្សព្វផ្សាយពីច្បាប់ដែលជាប់និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ប្រជាពលរដ្ឋ
ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទ រៀបចំផែនការប្រចាំខែ និងត្រីមាស
សហការជាមួយស្ថាប័នជំនាញសមត្ថកិច្ចនិងសហគមន៍ជិតខាងក្នុងការបង្ក្រាបបទល្មើសនេសាទ ៣ដង/ខែ
៦.ផែនការចរិការគ្រប់គ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ
ភាគទានពីសមាជិកសហគមន៍
ភាគទានប្រចាំឆ្នាំ

បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
ដើម្បីពិនិត្យ និងសម្រួល
កំពត...ថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ២០១៧
នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត

ឫក សំអុល

លេខ : 052/17
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត
ដើម្បីពិនិត្យ និងសម្រួល
បឹងទូក, ថ្ងៃទី 14 ខែ កុម្ភៈ ឆ្នាំ២០១៧
មេឃុំបឹងទូក

មូល សុខុម

សូមគោរពជូន
លោកមេឃុំបឹងទូក
ដើម្បីពិនិត្យ និងសម្រួល
ទទឹងថ្ងៃ, ថ្ងៃទី 14 ខែ កុម្ភៈ ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទកែបថ្មី

លេខ : ៦៤៣៤
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៧
ប្រតិភូកម្មាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

អេង ជាសាន

លេខ : ៦៤៣៤
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និងសម្រេច
កំពត ថ្ងៃទី ៤៤ ខែ កុម្ភៈ ឆ្នាំ២០១៧
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត

ចាន់ រិទ្ធិ

លេខ : ៦៣៤ ខ.រ.ក.ព
បានឃើញ និងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកំពត
ដើម្បីពិនិត្យ និងសម្រួល
កំពត ថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ២០១៧
នាយខណ្ឌរដ្ឋបាលជលផលកំពត

ស_សុរិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ ៖ កែបថ្មី
ភូមិ ៖ កែបថ្មី
ឃុំ ៖ បឹងទូក
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៥៤៤ ប្រក.កសក

ប្រកាស
ស្តីពី
ការបុះបញ្ជីសហគមន៍នេសាទចំនួន១៤ នៅខេត្តត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ ពោធិ៍សាត់ កំពត និងខេត្តកោះកុង

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Add: 200 Preah Norodom Blvd. Sangkat Tonle Basak. Khan Chamkarmon, Phnom Penh. Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129. Fax: (855) 23-217 320

សម្រេច

ប្រការ ១._

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់សហគមន៍នេសាទចំនួន១៨ រួមមាន៖ ខេត្តស្វាយរៀងចំនួន០៣ សហគមន៍នេសាទ ខេត្តព្រៃវែងចំនួន០១សហគមន៍នេសាទ ខេត្តកណ្តាលចំនួន០២សហគមន៍នេសាទ ខេត្តតាកែវ ចំនួន០៤សហគមន៍នេសាទ ខេត្តពោធិ៍សាត់ចំនួន០១សហគមន៍នេសាទ ខេត្តកំពតចំនួន០២សហគមន៍នេសាទ និងខេត្តកោះកុងចំនួន០១សហគមន៍នេសាទ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះ ភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗ ជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

ប្រការ ២._

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ១ អាចកែប្រែបានតាមការចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៣._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤._

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទេព សោខុន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ៖ ភ្ជាប់ប្រកាសលេខ.....[illegible].....ចុះថ្ងៃទី.....[illegible].....ខែ.....[illegible].....ឆ្នាំ២០១៧

សហគមន៍នេសាទក្នុងខេត្តត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ ពោធិ៍សាត់ កំពត និងខេត្តកោះកុង

ល.រ	ឈ្មោះសហគមន៍នេសាទ	ចំនួនសមាជិក	ចំនួនសមាជិកគណៈកម្មការសហគមន៍	ទំហំផ្ទៃសហគមន៍ (ហិកតា)	ភូមិ	ឃុំ/សង្កាត់	ស្រុក/ក្រុង	Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter	
								(X,Y)	(X,Y)
១. ខេត្តត្បូងឃ្មុំ									
០១	បឹងក្រពិត	៤៤៧	១១	៣.២៨៣	-កន្លែងចក	-មៀន	អូររាំងឌ៉	A(551203,1315424)	J(548923,1300095)
					-ស្វាយពក	-ព្រះធាតុ		B(550065,1314183)	K(547205,1301471)
					-ថ្មី			C(550186,1314172)	L(546384,1303712)
					-ថ្មសំលៀង			D(550641,1314662)	M(547623,1306251)
					-បឹងជើង			E(551347,1313897)	N(548175,1305698)
					-មៀន			F(553399,1314972)	O(549345,1305371)
					-សោយ			G(553222,1315896)	P(549254,1306021)
					-មេលោង				Q(550841,1306049)
					-កំពូលសេរី			A(549743,1312788)	R(552311,1306894)
					-បន្ទាយមៀន			B(549342,1312058)	S(551713,1308557)
					-បឹងកណ្តាល			C(549192,1309122)	T(550862,1309129)
					-បឹងកាង			D(545981,1307122)	U(551949,1310348)
					-ស្រែមៀន			E(545209,1306017)	V(552296,1311075)
					-ទួលឃ្លាំង			F(545677,1304424)	W(551654,1312041)
					-ទួលមានជ័យ			G(544916,1303471)	X(551145,1311885)
					-បាស្រី			H(546371,1300906)	Y(551041,1312399)
								I(547959,1299938)	Z(550662,1312525)

					-ព្រះធាតុកណ្តាល -ព្រះធាតុថ្មដា				
០២	រការពប្រាំ	២៧៧	១១	២២៦	-ប្រជាត់ -ឈូកសណ្តាល់	រការពប្រាំ	ត្បូងឃ្មុំ	A(569218,1338588) B(569279,1338436) C(569182,1337444) D(568754,1336116) E(567924,1337295)	F(567549,1338895) G(568041,1338112) H(568543,1337981) I(568596,1338036) J(568498,1339009)
០៣	សំបុកសត្វសែនជ័យ	២៤៥	១១	៧.៤៣០	-ទួលរការ -ទួលអុក -ទួលស្នួល -ទួលគ្រាច -ទួលតាកោថ្មី -មុខភ្នំ -សង្គមមានជ័យ	ទួលស្នួល	ក្រូចឆ្មារ	A(569212,1338595) B(570487,1339768) C(570777,1340225) D(570856,1340516) E(568733,1342559) F(570279,1346054) G(573397,1346361)	H(576168,1346367) I(578051,1345302) J(578862,1346584) K(577289,1347485) L(572421,1349838) M(562941,1347463) N(565348,1341624)
២. ខេត្តព្រៃវែង									
០១	ព្រែកតាសរ	១.៤៤៦	១១	៣.៧៩០	-ព្រែកតាសរ -តាព្រះ -ព្រែកឈ្មោះ -ព្រែកក្រូច	ព្រែកតាសរ	ពោធិ៍រៀង	A(522036,1273470) B(521578,1274284) C(520216,1280352)	D(518565,1280347) E(513696,1277412)
៣. ខេត្តកណ្តាល									
០១	កោះកែវ	២១៩	៩	៣៨,២	-កោះកែវលើ -កោះកែវក្រោម			A(526383,1264051) B(526345,1264094) C(526311,1264027) D(526232,1263989)	K(524272,1265307) L(524225,1265192) M(525142,1264761) N(525102,1264703)

								E(525905,1264378) F(525140,1264683) G(525179,1264740) H(525224,1264703) I(525375,1264653) J(525281,1264754)	O(524449,1264843) P(524438,1264793) Q(525779,1264210) R(526231,1263980) S(526318,1264016)
០២	ទួលមុខវាន	៤៥៩	១១	៦.៣៨០	-ព្រែកតូច -ព្រែកបាក់ -ស្ពានដែក -អំពិលទឹក -កំពង់ពោធិ៍ -កោះចំរើន	-ព្រែកទម្លាប់ -កំពង់ភ្នំ	លើកដែក	A(522008,1239018) B(518923,1239011) C(519954,1240838) D(519303,1240906) E(517467,1239009)	F(517966,1241369) G(518005,1248759) H(518472,1250000) I(521999,1250000)
៤. ខេត្តតាកែវ									
០១	កំពង់រាប		១១		-កំពង់រាប -កំពង់លាវ -កំពង់សាម៉ី -ពាម -ជំនិត -កញ្ជិល	កំពង់រាប	ព្រែកឃ្លាស	A(490349,1225943) B(497267,1225865) C(497602,1225745) D(497224,1225538)	E(499134,1224239) F(498738,1224153) G(497852,1224317) H(490375,1224136)
០២	គោកពោធិ៍	២០២	៧	៣.៥៩០	-ជ្រៃគោកពោធិ៍ -ព្រៃហៀវ -កំពង់យោល -ពងទឹក -ព្រៃមូល		ជ្រៃគោកពោធិ៍	A(489845,1201005) B(491999,1200989) C(492007,1201986) D(494152,1201984)	E(500533,1201981) F(498459,1203811) G(496525,1205956) H(489889,1205981)

					-អ្នកតាត្បាល់				
០៣	អង្គាញ់	២០៨	៧	១.២៦៧	-ត្រពាំងរកា -ផ្សារជ្រៃ -បានយ -ស្វាយពារ -ព្រីង -អង្គាញ់	អង្គាញ់	ព្រៃកប្បាស	A(490349,1225943) B(497267,1225865) C(497602,1225745) D(497224,1225538) E(499134,1224239) F(498738,1224153)	G(497852,1224317) H(490375,1224136)
០៤	អង្គរបូរី	២១៥	៧	៤.៧៨១	-កំពង់ហ្លួង -សាមគ្គី -ទួលសាំងក -ទួលសាំងខ -ស្ទឹងកំបុត -ព្រៃសំបូរ	អង្គរបូរី	អង្គរបូរី	A(496981,1220256) B(496986,1217022) C(499633,1217021) D(499771,1215563) E(499332,1214654) F(498681,1214539) G(497784,1214945) H(496936,1214828) I(497035,1214434) J(495479,1213274) K(494371,1210131)	L(495516,1210031) M(496477,1208732) N(495418,1207093) O(493636,1209601) P(493541,1212245) Q(491986,1211779) R(491983,1216005) S(492721, 1215987) T(492761, 1217895) U(492791, 1219059) V(492821, 1220298)
៥. ខេត្តតាកែវ									
០១	បឹងគុជនប់	៦៧	១១	៣០,៩៥	ក្រឡាញ់			A(418537,1375461) B(418416,1375851) C(418311,1376298) D(418170,1376492) E(417937,1376763) F(417934,1376819)	P(419126,1374299) Q(419041,1374246) R(419058,1374013) S(418961,1374011) T(418971,1374258) U(419095,1374362)

								G(418200,1376916) H(418429,1376891) I(418533,1376750) J(418134,1376758) K(418386,1376355) L(418461,1375861) M(418574,1375467) N(418818,1374711) O(419144,1374453)	V(419071,1374445) W(418761,1374677) X(418499,1375355) A_1(417934, 1376819) B_1(418075, 1376894) C_1(418200, 1376916) D_1(418319, 1376923) E_1(418429, 1376891) F_1(418533, 1376750)
៦. ខេត្តកំពត									
០១	តែបថ្មី	១០៦	៧	៦៨៣	តែបថ្មី	បឹងទូក	ទឹកឈូ	A(405681,1167459) B(405827,1167513) C(406019,1167525) D(406014,1167455) E(405672,1167411) F(405012,1166913) G(404843,1166815) H(405015,1166377) I(405488,1166123) J(406432,1166164) K(407211,1163706)	L(405195,1163525) M(403893,1166776) N(404377,1166957) Q(404605,1166965) R(404732,1167125) S(404648,1167386) T(405279,1167778) U(405332,1167822) V(405614,1167849) W(405469,1167585)
០២	ទទឹងថ្ងៃ	១៣១	៧	៧៧៦	ទទឹងថ្ងៃ			A(409761,1169363) B(407911,1166878) C(409091,1166325) D(409431,1163941) E(407211,1163706)	L(406697,1167679) M(406822,1167662) N(406957,1167584) Q(407305,1167497) R(407502,1167185)

								F(406432,1166164) G(407022,1166243) H(407409,1166541) I(407677,1166981) J(407406,1167078) K(406698,1167562)	S(408006,1167415) T(407609,1167805) U(407449,1167945) V(407576,1168061) W(407817,1167799) X(409052,1168009)
៧. ខេត្តកោះកុង									
០១	ជ្រោយស្វាយ	១.៩២៦	៩	១៣.៤៤៣	-ជ្រោយស្វាយលិច -ជ្រោយស្វាយកើត -កំពង់ស្តាំ -សាវ៉ាយ -ភ្នំស្រឡៅ -នេសាទ	ជ្រោយស្វាយ	ស្រែអំបិល	A(339991,1223055) B(353912,1223034) C(353920,1222474) D(352692,1221779) E(352706,1221335) F(354137,1219335) G(354346,1218317) H(354028,1217752)	I(354493,1215824) J(354353,1215798) K(354263,1216026) L(353796,1215828) M(356779,1215655) N(357377,1215551) O(348979,1215613)

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ក្រសាបរដ្ឋបាលជលផល

អេង ជាសាន

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧ៣ ឆ្នាំ២០១៧
ជ្នេមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទេង សាខុន